# ការពិតនៅលើអ្វីដែលគេហៅថា "សង្គ្រាមស៊ីវិល" នៅស្រុកខ្មែរ

ដោយ ចៅ-សេងអួរ
អតីតរដ្ឋមន្ត្រីខ្មែរ

មកដល់សព្វថ្ងៃនេះទៀត ស្តីពីប្រតិបត្តិការណ៍សឹកនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ គេនៅតែនិយាយថា<ចំបាំងស៊ីវិល> រវាងខ្មែរនិងខ្មែរក្នុងស្រុកដដែល ។ គេក៏នៅតែនិយាយថា មានការបំពានពីសំណាក់អាមេរិកាំងក្នុងឆ្នាំ១៩៧០ ទៅលើប្រទេសខ្មែរដែលជាអ្នកត្រូវរងគ្រោះ ។

ការពិតគឺមានការរំលោភពីបរទេសយ៉ាងជាក់ស្តែងលើប្រទេសខ្មែរ ចាប់ពីថ្ងៃ ២៩ មិនា ឆ្នាំ១៩៧០ ក៏ប៉ុន្តែការរំលោភនេះជាស្នាដៃរបស់ទ័ពកុម្មុយនិស្តយួន ដែលបានចូលដោយសម្ងាត់ក្នុងទឹកដីខ្មែរ តាំងពីដើមឆ្នាំ១៩៦០មកម្ល៉េះ ។ ការរំលោភធ្វើឡើងដោយឥតបានដាក់កំរិតជាឱសានវាទនិងគ្មានការប្រកាសសង្គ្រាមទេ ។ ទ័ពយៀកកុងនិងហាណូយបានដកបុគ្គលិកទូតទាំងអស់ពីភ្នំពេញនៅថ្ងៃ២៧ មិនា ១៩៧០ ។ យៀកកុងនិងហាណូយបានប្រកែកទាំងបំពានទៅលើការពិតនៃកម្លាំងទ័ពនិងជំរករបស់ខ្លួននៅស្រុកខ្មែរ ទោះជាពេលនោះសម្តេចសីហនុបានបរិហារចង្អុលបង្ហាញនៅឆ្នាំ១៩៦៨-៦៩ក៏ដោយ ។ «កុម្មុយនិស្តយួនលួចចូលស្រុកយើងច្រើនឡើងៗ ខ្ញុំមិនអាចលាក់បានទៀតទេ ដល់ពេលដែលត្រូវឲ្យមតិអន្តរជាតិដឹងឮហើយ», សម្តេចសីហនុបានប្រកាសក្នុងសន្និសិទកាសែតនៅភ្នំពេញ នៅថ្ងៃ២៨មិនាឆ្នាំ១៩៦៩ (ដកស្រង់ពីឯកសារស្តីពីការឈ្លានពានរបស់យៀកកុងនិងហាណូយលើស្រុកខ្មែរ បោះផ្សាយដោយក្រសួងឃោសនាការនៅភ្នំពេញ <១៩៧០> ។

បើគេពិនិត្យលើថ្ងៃខែនៃព្រឹត្តិការណ៍តាមលំដាប់លេខរៀងនៃការកើតមានឡើងនាពេលនោះ កាលបរិច្ឆេទនេះចង្អុលឲ្យឃើញយ៉ាងច្បាស់ថាគ្មានការរំលោភឬឈ្លានពាន ពីសំណាក់អាមេរិកាំងនៅឆ្នាំ១៩៧០ទេ ។ ព្រោះថា គឺនៅថ្ងៃ៣០មេសាឆ្នាំ១៩៧០ គឺមួយខែក្រោយពីការឈ្លានពានរបស់យួនកុម្មុយនិស្តនោះទេ ទើបបានទ័ពអាមេរិកាំងនិងទ័ពយួនខាងត្បូងចូលធ្វើអន្តរាគមន៍មកលើស្រុកខ្មែរ ហើយមានបំណងតែមួយគត់គឺបំផ្លាញជំរករបស់យួនកុម្មុយនិស្ត ដែលតាំងនៅខាងកើតស្រុកខ្មែរ ។

គឺចេញពីតំបន់ខាងកើតនេះហើយ ដែលកុម្មុយនិស្តយួនចូលទៅវាយប្រហារជារឿយៗ ទៅលើស្រុកយួនខាងត្បូង ដូចជាការវាយប្រហារមួយយ៉ាងធំនៅពេលបុណ្យចូលឆ្នាំ têt ឆ្នាំ១៩៦៨ជាដើម ។ អន្តរាគមន៍របស់អាមេរិកាំងនេះទៀត គឺធ្វើឡើងនៅក្នុងកំរិតច្បាស់លាស់ មានកំរិតពេលវេលានិងកំរិតទំហំដី ៖ គឺក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃ៣០មេសាដល់ថ្ងៃ៣០មិថុនាឆ្នាំ១៩៧០ ហើយក្នុងជំរៅដីជិត៣០គ.ម.តែប៉ុណ្ណោះ ។ ក្រោយពីនោះមក លែងមានទ័ពជើងគោកអាមេរិកាំងប្រតិបត្តិការនៅក្នុងស្រុកខ្មែរទៀតហើយ ។

ដូច្នេះគ្មានអាចមានចំបាំងស៊ីវិលរវាងខ្មែរនិងខ្មែរនៅក្នុងស្រុកនាឆ្នាំ១៩៧០ទេ ដោយហេតុថា សម្តេចសីហនុគ្មានកងទ័ពនៅក្រោមបង្គាប់លោកទេ ក្រោយពេលដែលគេដកលោកចេញពីតំណែងនៅថ្ងៃ១៨មិនា ។ ឯខ្មែរក្រហមវិញនៅពេលនោះ គេគ្មានទ័ពធំទេ ព្រោះចលនាគេត្រូវបានស្តេចសីហនុរំលាយអស់ហើយ ក្នុងរយៈពេល៣ឆ្នាំក្នុងក្របខ័ណ្ឌនៃការកំចាត់បង្ក្រាបរបស់ស្តេចសីហនុពីឆ្នាំ១៩៦៧, ៦៨, ៦៩ ។

ដូច្នេះ នៅឆ្នាំ១៩៧០, ៧១, ៧២ រហូតដល់ពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសពីរឿងយួន នៅថ្ងៃ២៧ មករា ១៩៧៣ គឺមានតែទ័ពយួនកុម្មុយនិស្តប៉ុណ្ណោះទេ ដែលបិតនៅចំពោះមុខទ័ពរដ្ឋាភិបាលខ្មែរ ។ រូបថតនិងឯកសារជាច្រើន ដែលបោះផ្សាយដោយក្រសួងឃោសនាការខ្មែរពេលនោះ ជាភស្តុតាងស្រាប់ (រូបថតខ្មោចសត្រូវ អាវុធនិងឯកសាររបស់សត្រូវ) ។ល។ គឺនៅពេលក្រោយ ពីកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសនេះទេ ដែលកងទ័ពខ្មែរក្រហមបង្ហាញវត្តមានជាមួយទ័ពយួននៅទីសមរភូមិ ។

មាត្រា២០នៃកិច្ចព្រមព្រៀងនៅក្រុងប៉ារីសបានចែងថា ទ័ពបរទេសនានាត្រូវតែដកចេញពីដីខ្មែរនិងលាវ ។ គ្មាននរណាមួយមិនដឹងទេថាតើទ័ពបរទេសនោះ ជាទ័ពនៃប្រទេសណានេះ ។ ក៏ប៉ុន្តែទ័ពបរទេសនេះមិនបានដកថយចេញពីស្រុកខ្មែរទេ គេគ្រាន់តែយកទ័ពខ្មែរក្រហមមកដាក់នៅពីមុខទ័ពគេប៉ុណ្ណោះ ។ ទ័ពខ្មែរក្រហមនេះ ដែលជាសម្ព័ន្ធមិត្តរបស់យួនហាណូយបានរង់ចាំរហូតជិតបីឆ្នាំ ទើបអាចបង្កើតបានជាទ័ពមួយនៅក្នុងតំបន់ខ្មែរដែលយួនយៀកកុង-យៀកមិញបានរាតត្បាតក្នុងឆ្នាំ១៩៧០ ។ បើប្រសិនណាជាមានចំបាំងរវាងខ្មែរនិងខ្មែរកាប់សម្លាប់គ្នាឯងពាសពេញប្រទេស ជាពិសេសនៅរាជធានីនិងទីក្រុងធំៗនោះហើយ ប៉ុន្តែគ្មានរឿងកាប់សម្លាប់ដូចនេះសោះ ។

ក្រោយពីកិច្ចព្រមព្រៀងប៉ារីសក្នុងឆ្នាំ១៩៧៣-១៩៧៤ ខ្មែរក្រហមដែលជាដៃជើងយួន និងបង្កើតដោយយួនកុម្មុយនិស្ត មានចំនួនតិចតួចណាស់ មិនអាចធ្វើអ្វីបាននៅពេលនោះទេ បើគ្មានការគាំទ្រគ្រប់បែបយ៉ាង មានការដឹកជញ្ជូនគ្រឿងសព្វាវុធពីសំណាក់កងទ័ពយួនដែលតាំងនៅក្នុងស្រុកខ្មែរ ដែលជាការបំពានលើមាត្រា២០នៃកិច្ចប្រជុំនៅប៉ារីស ។

មានអ្នកកាសែតបរទេស ដែលភាគច្រើនជាអ្នកកាសែតបស្ចឹមប្រទេស ប្រហែលជាង៣០នាក់បានបាត់ខ្លួននៅក្នុងស្រុកខ្មែរ ក្នុងរយៈវេលា៣ខែដំបូងដែលសង្គ្រាមបានចាប់ផ្តើម ។ បើប្រសិនមានសង្គ្រាមខ្មែរនិងខ្មែរពិតមែននោះ ការឃោសនាដែលអួតអាងថា គេជាទ័ពរបស់សីហនុនោះអាចនឹងមានផលប្រយោជន៍ច្រើនណាស់ បើគេយកអ្នកកាសែតទាំងនោះមកធ្វើជាកសិណសាក្សី ថាគ្មានទ័ពយៀកកុងនិងយួនខាងជើងនៅក្នុងស្រុកខ្មែរទេ ។ ផ្ទុយទៅវិញ គេគ្មានឃើញអ្នកកាសែតណាម្នាក់បានត្រឡប់មកវិញឡើយ ។ និយាយឲ្យខ្លី រឿងប្រឌិតថាមានចំបាំងស៊ីវិលក្នុងស្រុករវាងខ្មែរនិងខ្មែរ ជារឿងមួយបង្កើតទាំងស្រុងពីសំណាក់យួនហាណូយនិងរណបរបស់គេគឺយៀកកុង ដើម្បីបំបិទបំបាំងអំពើឈ្លានពាននៃកម្លាំងទ័ពរបស់គេក្នុងស្រុកខ្មែរនៅឆ្នាំ១៩៧០តែប៉ុណ្ណោះ ។ សាក្សីដែលរំខានប្រយោជន៍គេ ដូចជាអ្នកកាសែតបរទេសទាំង៣២នាក់ដែលបាត់ខ្លួននោះ ត្រូវគេសម្លាប់ចោលតែម្តង ។ ជាអកុសលថែមទៀតមតិនៃបស្ចឹមប្រទេសបានបណ្តោយខ្លួនឲ្យមជ្ឈដ្ឋាន សារពត៌មានធំៗបំភ័ន្តបាន ហើយជាញឹកញាប់សារពត៌មានធំៗទាំងនោះ តែងទោរទន់ស្រឡាញ់អនុគ្រោះកុម្មុយនិស្តយួន ហើយប្រឆាំង<អ្នកចក្រពត្តិនិយម> ។ សព្វថ្ងៃ ការនិទានប្រឌិតនៅតែបន្តរហូត ។ រីឯការពិតជាប្រវិត្តសាស្រ្តដែលគេបានក្លែងបំភ័ន្តជាច្រើនឆ្នាំមកហើយនោះ គឺពិបាកកែផ្លាស់ប្តូរឲ្យត្រឡប់មកតាមសភាពដើមឡើងវិញណាស់ ។ ក៏ប៉ុន្តែជាការសំខាន់ណាស់ សំរាប់យុវជនយើង ដែលត្រូវដឹងច្បាស់ពីប្រវត្តិសាស្រ្តពិតរបស់ស្រុកខ្លួន ។៚

# La vérité sur une fausse ' guerre civile au Cambodge

Aujourd'hui encore on continue de parler de « Guerre Civile » à propos des opérations militaires qui eurent lieu au Cambodge dans les années 1970-1975. On parle aussi d'une agression américaine dont le Cambodge aurait été victime en 1970.

En réalité, il y eut une agression étrangère caractérisée contre le Cambodge à partir du 29 Mars 1970, mais elle fut le fait des forces VC/NVN infiltrées en territoire Khmer depuis le début des années 60. Cette agression fut déclenchée sans ultimatum et sans déclaration de guerre. Le Vietcong et Hanoï avaient retiré tout leur personnel diplomatique de Phnom Penh le 27 Mars 1970. Et pour cause, puisque le Vietcong et Hanoï niaient - contre toute évidence - la présence de leurs troupes et l'existence de leurs ' sanctuaires ' au Cambodge, alors que le Prince Sihanouk- les avait, lui-même dénoncés en 1968 et 1969.

« Les Communistes Vietnamiens s'infiltrent de plus en plus chez nous. Je ne peux plus le cacher. Il est temps que l'opinion mondiale le sache », déclare le Prince Sihanouk dans Une conférence de Presse à Phnom Penh le 28 Mars 1969. [ Documents sur l'agression Vietcong et à Nord-Vietnamiens contre le Cambodge ( 1970 édités par le Ministère de l'Information à Phnom Penh]

La chronologie des événements fait clairement apparaître qu'il n'y eut aucune agression ou 'invasion' américaine en 1970. En effet, ce ne l'ut que le 30 Avril - un mois après le début de l'agression VC/NVN - que les forces américaines et sud-vietnamiennes intervinrent au Cambodge uniquement pour détruire les « Sanctuaires des Communistes Vietnamiens » installés dans tout l'Est du pays, et de là ils lancèrent de fréquentes attaques contre le territoire sud-vietnamien dont la grande offensive du 'Têt' de 1968. Cette intervention fut strictement limitée dans le temps et dans l'espace : deux mois ( 30 Avril - 30 Juin 1970), et sur une profondeur de 30 km seulement.

Après cela. il n' y eut plus jamais de forces terrestres américaines opérant au Cambodge. Il ne pouvait pas y avoir de « Guerre civile » dans ce pays en 1970 pour la simple raison que Sihanouk ne disposait d'aucune troupe à ses ordres après sa destitution le 18 Mars. Quant aux Khmers Rouges, ils ne comptaient pas à cette époque - **leur mouvement ayant été complètement laminé par trois années de répression de Sihanouk ( en 1967, 68 et 69 )**

En 1970, 1971 et 1972 jusqu'à la signature des accords de Paris sur le Vietnam du 27 Janvier 1973, **les forces gouvernementales cambodgiennes n'eurent donc en face d'elles que les forces étrangères Vietcong et Nord-Vietnamiennes**. De multiples photos et documents, publiés à l'époque par le Ministère de l'information Cambodgien en témoignent ( photos de cadavres ennemis, armes et documents pris à l'ennemi etc-) **Ce n'est qu'après les accords de Paris que des forces composées de Khmers Rouges apparurent sur les théâtres d'opérations cambodgiennes**.

En effet. l'article 20 de ces accords stipulait que toutes les 'forces étrangères' devraient se retirer des territoires du Cambodge et du Laos. Personne n'ignorait de quelles 'forces étrangères' 'il s'agissait. **Mais, celles-ci ne se retirèrent pas du territoire cambodgien, elles se contentèrent de mettre désormais en première ligne leurs alliés, les Khmers Rouges qui avaient eu presque trois**

**ans pour se constituer une armée dans les provinces envahies par les forces VC/NVN en 1970**.

S'il y avait eu réellement une guerre civile on aurait vu les Khmers s'entre-tuer partout et notamment dans la Capitale et les principales villes, ce qui ne fut jamais le cas. **Les Khmers Rouges, créatures des communistes Vietnamiens étaient d'ailleurs peu nombreux et ils n'avaient rien pu faire en 1973 et 1974** ( après les accords de Paris ) **sans le soutien logistique des forces communistes Vietnamiennes restées au Cambodge en violation de l'article 20 de ces accords**.

Plus d'une trentaine de journalistes étrangers, en majorité occidentaux ont disparu au Cambodge dans les premiers mois de la guerre. S'il s'était agi vraiment d'une ‘guerre civile’, la propagande des soi-disant ‘forces de Sihanouk’ aurait eu tout intérêt à les utiliser pour qu'ils témoignèrent qu'il n'y avait pas de forces VC/NVN opérant au Cambodge. Au lieu de cela, aucun de ces journalistes na jamais reparu.

En résumé, le mythe d'une ‘Guerre Civile’ a été fabriqué de toute pièce par Haoï et son satellite. le Vietcong pour camoufler l' agression de leurs forces contre le Cambodge en 1970. Les témoins gênants, comme les 32 journalistes étrangers disparus, ont été purement et simplement ‘liquidés’. **Malheureusement, l'opinion occidentale s'est laissée abuser par de grands media, souvent très orientées dans un sens favorable aux Communistes Vietnamiens » anti-impérialistes'**. Le mythe perdure aujourd'hui et la vérité historique travestie depuis des années, sera difficile à rétablir. Cependant, **il est très important que la jeunesse Khmère apprenne l'Histoire authentique de son pays**.

CHAU XENG UA
Ancien Ministre